ខ្ញុំគួរតែមកដល់ Parisនៅម៉ោង៦ល្ងាច ប៉ុន្តែយន្តហោះមានបញ្ហាបានជារុញម៉ោងរហូតដល់ជាង៩យប់។ ក្រុងប៉ារីសរឹតតែអស្ចារ្យពេលមើលឃើញផ្ទាល់ភ្នែក ហើយស្ថិតក្នុងពេលរាត្រីចិញ្ចាចចិញ្ចែងបែបនេះ។

ដៃខ្ញុំរាវរកបាច់ផ្កាដែលម្ដាយខ្ញុំបានឱ្យមុនពេលឡើងយន្តហោះមកពីស្រុកខ្មែរ។ ជានិច្ចកាល សម្ដីម៉ែនៅរងំជានិច្ចក្នុងរង្វង់បេះដូងខ្ញុំ។

«ទៅទីណាក៏ដោយ ក្លាយជាអ្នកមានបានប៉ុនណាក្ដី ត្រូវរក្សាចរិតជាស្ត្រីខ្មែរ រក្សាតួនាទីជាភរិយា រក្សាមេត្តាធម៌ក្នុងនាមពុទ្ធសាសនិកណ៎ាឡានី កូនល្អរបស់ម៉ែ!!!»

ឱវាចាម៉ែពិតជាកក់ក្ដៅណាស់សម្រាប់កូន!

ខ្ញុំចេញពីយន្តហោះភ្លាមឃើញអ្នកមកចាំទទួលត្រៀបត្រា។

ក្នុងចំណោមពួកគេគ្មានអ្នកណាជាជនជាតិយើងទេ គឺមានតែស្វាមីជាទីស្រលាញ់ខ្ញុំម្នាក់គត់ដែលខ្ញុំស្គាល់ ហើយឥឡូវនេះ ខ្ញុំជាស្រីតែម្នាក់គត់ទៀតក្នុងចំណោមពួកគេ។

ការភ័យខ្លាចរបស់ខ្ញុំបានថយចុះ នៅពេលគេលូកដៃមកកាន់ខ្ញុំ....

«ស្រុកបារាំងស្អាតទេ ឡានី?!»

គេសួរខ្ញុំជាមួយសំឡេងតូចស្រាលរបស់គេ។

សំឡេងគេពីរោះ នៅចាញ់ស្នាមញញឹមរបស់គេដែលសង្ហាដូចប្រុសអឺរ៉ុបនេះ កុំតែគេមានភ្នែកខ្មៅក្រឹប និងនិយាយខ្មែរច្បាស់។

ខ្ញុំនឹកដល់ម្ដាយខ្ញុំទៀតហើយ.....

«កូនប្រុសលោកទូតឆ្លងសមុទ្រមករកគូព្រេងដល់ដីស្វាយរៀង គិតទៅគេថាគូព្រេងមិនព្រាត់មែន! សំណាងអីសំណាងម្ល៉េះ កូនស្រីខ្ញុំអើយ! ស្វាមីបុណ្យសក្ដិធំ រូបរាងស្រស់សង្ហា ទៅណាបរិវាឆ្វេងស្ដាំ!»

ខ្ញុំញញឹមព្រោះដៃរបស់គេលើកមកក្រសោបដល់ស្មាខ្ញុំ។

គេឈ្មោះបងរិទ្ធ។ គេមិនងាយស្រលាញ់ស្រីណាទេ នេះបើតាមប្រសាសន៍ប៉ាក្មេកខ្ញុំ។ មនុស្សគេនេះចូលចិត្តសេរីភាព រស់នៅស្ងប់ស្ងៀម ស្រលាញ់ធម្មជាតិ ហើយស្រលាញ់ជាតិខ្វាប់ខ្ជួន។

គេមកនៅស្រុកបារាំងតាំងពីក្មេង តែនៅរក្សាការនិយាយភាសាខ្មែរបានយ៉ាងមធ្យម ហើយស្រលាញ់គោរពនារីខ្មែរក្នុងឥរិយាបថសុភាពរម្យទម។

ខ្ញុំនឹកទៅដល់ប៉ុន្មានមុននេះ... នៅស្វាយរៀង....

«គេឈ្មោះរិទ្ធ! សេដ្ឋារិទ្ធ កូនប្រុសអ្នកមានទៅនៅបារាំងតាំងពីតូច! ពូជពង្សជាអ្នកមានជាអ្នកធំ! ប៉ាគេជាអ្នកការទូតណ៎ាកូនម្ដាយ! កូនម៉ែនឹងក្លាយជាលោកជំទាវមិនខានទេ!»

«ចុះហេតុអីបានជាគេមកជ្រើសរើសយកមនុស្សសាមញ្ញដូចកូនជាភរិយាទៅម៉ែ?»

ម្ដាយខ្ញុំនៅស្ងៀមស្ងាត់។ ខ្ញុំដឹងថាលោកក៏ពិបាកចិត្តចំពោះបុណ្យវាសនាដ៏ខ្ពស់សម្បើម តែទីបំផុតលោកខំកាត់ចិត្តលួងលោមកូនស្រី។

«កុំគិតអ្វីស្មុគ! នេះហើយដែលចាស់លោកហៅថាបុណ្យ! បុណ្យវាសនានេះមិនអាចមើលស្រាលទេណ៎ាកូន! ពាក្យចាស់លោកថា ដែងអ្វីដែងបាន ដែងព្រេងសំណាងក្រែងដែងទៅពុំរួច?!!»

យើងមិនទាន់បានផ្សំដំណេកទេតាំងពីរៀបការរួច ព្រោះយប់ថ្ងៃការនោះ ខ្លួនគេត្រូវមានបេសកកម្មឡើងទៅភ្នំពេញ។

ពេលនេះខ្ញុំមកដល់ស្រុកបារាំង ឆ្ងាយណាស់ពីព្រំដែនស្វាយរៀងឆៀងខាងកើតរបស់យើង។

«នារីស្រុកទន្លេ សាច់សហ្មត់រលោង!»

គេវាចាតិចៗចំអន់ខ្ញុំ តែចិត្តខ្ញុំចម្លែកដែលបុរសទាន់សម័យដូចគេនេះក៏ចេះនិយាយប្រយោគឃ្លោងឃ្លាដូចជាអ្នកនិពន្ធ។

«អត់និយាយអីសោះ មិននឹកប្ដីទេ?»

គេញញឹមទៀតហើយ បេះដូងខ្ញុំក៏រឹតតែកក់ក្ដៅថែមឡើង។

«បងរិទ្ធចង់ឱ្យឡានីនិយាយអី?»

ខ្ញុំសួរគេខ្សោយៗ គេក៏ឆ្លើយមកវិញស្រទន់ពីរោះ៖

«អីក៏បាន អីក៏បងរិទ្ធនៅស្ដាប់!»

ជំនិះយើងបានមកដល់ចុងមហាវិថី ហើយនឹងចាប់ផ្ដើមបត់វេរ ព្រមទាំងបង្កើនល្បឿនឡើងទៅកាន់ High way។ ចំណាប់អារម្មណ៍ដ៏ពិសេសរបស់ខ្ញុំ គឺថាពេលនេះយើងបានចាកចេញឆ្ងាយពីព្រលានយន្តហោះហ្សាលដឺហ្គោលដ៏ធំមហិមា ហើយត្របាញ់ឆ្ពោះទៅភាគខាងលិចក្រុងដោយឆ្លងកាត់ពីលើស្ពាន Pont de Bercyd ដ៏បុរាណរុងរឿង។

«ស្ពាននេះកសាងឡើងនៅក្នុងឆ្នាំ១៨៣២ ដើម្បីជំនួសការធ្វើដំណើរតាមនាវាចម្លងដែលមានភាពចង្អៀតលើសដែនកំណត់! មើលនៀកឡានី កន្លែងនេះគេកសាងដោយគិតដល់ថាត្រង់ណេះ សម្រាប់អ្នកថ្មើរជើង និងទីនេះសម្រាប់រទេះសេះ! នៅចន្លោះពីឆ្នាំ១៨៦៣ ឬ៦៤ អីហ្នឹងជាសម័យដែលពួកអភិជន និងរាជវង្សានុវង្សបារាំងនិយមប្រើរថដែលភ្ជាប់ជាមួយសេះពីរឬបួន! ទោះអ៊ីចឹងក៏ដោយ គេនៅតែ

ជឿថា អនាគតតមក ស្ថាននេះនឹងទទួលរថទំនើបច្រើនទៀត! ឃើញអត់? រចនាសម្ព័ន្ធរបស់ស្ថានកសាងពីប្រភេទថ្មរឹងមាំទាំងអស់!»

គេនេះមើលទៅហ្មត់ចត់ ហើយទុកខ្ញុំជាមនុស្សពិសេសពិតៗ ពីព្រោះខ្ញុំកំពុងតែមានអារម្មណ៍យ៉ាងពិសេសណាស់។ ព្រលប់ណាស់ទើបយើងមកដល់ Le Maraia ដែលជាសង្កាត់តូចមួយនៅកៀកនឹងប៉ារីស។ តំបន់នេះមានសំណង់ចាស់ៗភាគច្រើនជាលក្ខណៈរ៉ូម៉ាំងរំលេចពីលើដែនដីបៃតងនៃវាលទំនាប។

**« សណ្ឋាគារអីស្អាតយ៉ាងនេះ ?»**

**ខ្ញុំឆ្លេយមាត់ស្រាប់តែគេចាប់ស្មាខ្ញុំដោយដៃទាំងពីរហើយខ្សឹបខ្សៀវ៖**

**« ផ្ទះយើង ! មិនមែនអូតែលទេឡានី !»**

ខ្ញុំនៅស្រឡាំងកាំងដែលឮថាវិមានបុរាណដ៏មានតម្លៃនេះ តាមពិតគឺជាផ្ទះ។

គេឃើញអាកប្បកិរិយាខ្ញុំ គេយល់ចិត្តខ្ញុំក៏និយាយតទៅទៀត៖

«ទៅបន្ទប់សម្រាកសិន រៀបចំខ្លួន ចាំមកជុំអាហារពេលល្ងាចជប់លៀងរាត្រីដំបូងនៅប៉ារីស!» កែវភ្នែកគេធ្វើចិត្តខ្ញុំស្រៀវស្រើប។

គេជាសុភាពបុរសពិតៗស័ក្តិសមជាមួយប្រវត្តិពូជត្រកូលរបស់គេតែម្តង បានជាគេប្តូរពីពាក្យថា « រាត្រីទឹកឃ្មុំ» មកជា «រាត្រីដំបូងនៅប៉ារីស»។

គេនេះសមទាំងព្រម ទាំងចំណេះ សម្តីសំដៅការប្រព្រឹត្ត។

អ្នកបម្រើប្រុសម្នាក់មើលទៅដូចជាមិនមែនខ្មែរ ក៏មិនមែនបារាំង គេមកឱនកាយបង្ហាញផ្លូវខ្ញុំឆ្ពោះទៅរកជណ្តើរ។

ជណ្តើរវិមាននេះធំណាស់ ក្រាលដោយថ្មម៉ាបភ្លឺថ្លាដូចគជ់ពីលើដល់ក្រោម។

ខ្ញុំធ្លាប់បានធ្វើដំណើរទៅកាន់អាប៊ីសាអូឌីត ដោយសារក្រុមហ៊ុនខ្ញុំបញ្ជូនទៅចូលរួមសិក្ខាសាលា។ តែគំនូរធំៗនៅផ្ទះនេះគឺអស្ចារ្យ និងមើលទៅមានតម្លៃមហាសាលជាងសារមន្ទីរនៅទីនោះផង។

នៅបន្ទប់មួយដំបូងគេដែលហើបទ្វារតិចៗព្រោះកម្លាំងខ្យល់ត្រជាក់ ខ្ញុំក្រឡេកទៅឃើញសៀវភៅរាប់រយក្បាលរៀបចំយ៉ាងមានសណ្តាប់ធ្នាប់ ហើយទូសៀវភៅគឺលាតសន្ធឹងពេញតួជញ្ជាំង។

«បងរិន្ទពូកែអានសៀវភៅណាស់មែនទេ?» គ្មានចម្លើយតប។

ខ្ញុំបែរមករកអ្នកបម្រើ គេនោះនៅទ្រឹងដូចគល់ឈើ។

ខ្ញុំដឹងហើយ គេនោះមិនចេះភាសាអង់គ្លេសទេមើលទៅ?

អផ្សុកណាស់បើអ៊ីចឹង។ ខ្ញុំសម្លឹងមើលទៅជាន់ខាងក្រោម ស្វាមីខ្ញុំកំពុងនិយាយទូរសព្ទ។

រាងកាយគេមើលពីខាងណា ក៏នៅតែស្រស់សង្ហា ខ្ញុំភ្លឹកស្មារតីនឹកដល់ស្នេហាស្និតល្អិតដែលនឹងចូលមកដល់ក្នុងយប់នេះ ហើយជីវិតខ្ញុំគឺជារបស់គេ ចំណែកគេក៏ជារបស់ខ្ញុំ ហើយខ្ញុំនេះមេក្រុមបេឡាធិកាតូចតាចម្នាក់នេះ នឹងក្លាយជាម្ចាស់ស្រីនៃវិមានរាប់លានដុល្លារនេះមែនដែរទេ?

ខ្ញុំញញឹមរំភើបចំពោះអ្វីៗដែលកើតឡើងសឹងមិនគួរឱ្យជឿនេះ ស្រាប់តែគេបែរក្រោយ ហើយងើយមើលមកខ្ញុំដូចគ្នា។

ខ្ញុំថយគេចចេញក៏មិនទាន់ ដូច្នេះមានតែនៅដដែល ហើយគេញញឹមមករកខ្ញុំយ៉ាងកក់ក្ដៅ។ ខ្ញុំបែរមកវិញ ចាកចោលស្នាមញញឹមដែលគេមិនទាន់បញ្ឈប់វានៅឡើយ ទាំងនេះព្រោះតែខ្ញុំអៀន។

ខ្ញុំប្រឹងដើរឱ្យលឿនចូលដល់បន្ទប់គេង។

ទោះបីការជិះយន្តហោះឆ្លងទ្វីបខ្ញុំនេះមិនបានគេងគ្រប់ ហើយទោះបីជាពេលនេះគ្រែរបស់ខ្ញុំគឺមានផាសុកភាពបំផុត តែខ្ញុំគ្មានចិត្តចង់គេងទេ។ អ្នកបម្រើមិននិយាយមិនស្ដីនោះនៅឈរត្អុបមាត់ទ្វារបន្ទប់ មិនហ៊ានឈានចូលមកឡើយ ទុកឱ្យខ្ញុំនៅញញឹមកណ្ដាលបរិវេណបន្ទប់ដែលតុបតែងល្អវិចិត្រដោយសង្ហារិមពណ៌មាសដូចជាសយនា រាជានាសម័យដ៏បរមបុរាណ។

ស្វរផ្កេលូ?..... មិនទាន់យប់ស្រួលបួលផង? ឆ្កែស្រុកបារាំងលូថ្ងៃរណេះឬអ្វី?

អ្វីទាំងអស់ស្ថិតនៅក្រោមការសម្គាល់ឃើតៗរបស់ខ្ញុំ ហេតុអ្វីក៏វិមាននេះបិទជិត ហើយមានខ្យល់ត្រជាក់ជ្រៀតចូលមកបាន ហើយចូលមកមិនឈប់ឈរ? បង្អួចមិនបើកទេ មានស្វរផ្កេលូមកច្បាស់ម្ល៉េះ?

ខ្ញុំឱបដៃព្រោះទទួលអារម្មណ៍ថារងាម៉េចមិនដឹង ប្រុងងាកទៅសួរថាមានម៉ាស៊ីនកម្ដៅដែរ? តែពេលដែលឃើញមុខធ្មឹងរបស់អ្នកបម្រើប្រុសនោះ ខ្ញុំដូរចិត្តឈប់សួរវិញ ហើយបក់ដៃអនុញ្ញាតឱ្យគេនោះចាកចេញ។

ខ្ញុំឈោងដៃទាញទ្វារបុរាណដ៏ធំនោះបិទមកវិញ។

អូខេហើយ! ស្ងាត់ស្រួលណាស់ Selfie ផ្ញើរូបទៅម៉ែមួយសិនឬអ្វី?

បង្អួចហាក់ហើប?

ខ្ញុំបោះបង់ចោលគំនិតដែលថាថតរូប មកគយគន់ខាងក្រៅបន្ទប់វិញ។

មេឃខាងក្រៅងងឹតណាស់ មានតែពន្លឺផ្លុងៗនៃចង្កៀងរង្វើលៗក្នុងសួនច្បារ។

ទូរសព្ទរោទ៍មក ខ្ញុំបែរមកវិញ ហើយលើកស្ដាប់៖

«អាឡូ!»

«ខ្យល់ត្រជាក់ណាស់! កុំបើកបង្អួច!»

«អូយ! ម៉េចបងឯងដឹងខ្ញុំបើកបង្អួច?»

«បងទាយ!»

«អ៊ូ! ចេះទាយទៀតប្ដីខ្ញុំ?»

ខ្ញុំកំប្លុកកំប្លែងដាក់គេ គេសើចមកយ៉ាងពីរោះ។ ខ្ញុំសម្ងំស្ដាប់សូរសំណើចរបស់គេយ៉ាងមានសុភមង្គល។ សើចអស់ចិត្តទើបបងរិទ្ធបន្ថមកថា៖

«បងចាំនៅក្រោមណ៎ា! រៀបចំហើយ យើងមានលាងសាយភោជន៍!»

ខ្ញុំសើចក្អឹកៗនឹងសម្ដីគេ៖

«Party party ទៅ! លាងសាយភោជន៍អីទេ?»

«និយាយខ្មែរពីរោះជាងណ៎ាអូន!!»

គេនេះពិតជាជាតិនិយម បុរាណនិយម និងមានរសនិយមពិសេសខុសគេពេកហើយ។

មើលចុះពេលខ្ញុំចុះមកដល់បន្ទប់អាហារក៏ត្រូវភ្លឹកទៀតនឹងការរៀបចំយ៉ាងឧឡារិក។

គ្រប់យ៉ាងនៅលើតុដ៏វែងមួយ ហើយអាហារនីមួយៗទ្រលើជើងពានយ៉ាងប្រណីត សមតែជាអាហារនៃគ្រួសាររាជវង្ស។

«អីក៏ពិសេសម្ល៉េះ?»

ខ្ញុំលាន់មាត់ ហើយងាកមើលជុំវិញខ្លួន។

គ្មានមនុស្សណាផ្សេងម្នាក់សោះ សូម្បីតែអ្នកបម្រើម្នាក់ក៏គ្មានផង។ គឺរ៉ូមែនទិកដល់ហើយ មានតែគេហើយនិងខ្ញុំ។

តុនេះវែងពិតមែន តែមានកៅអីតែពីរប៉ុណ្ណោះ គឺនៅចុងម្ខាងដែលគេអង្គុយ ហើយចុងម្ខាងទំនេរនេះ សម្រាប់ខ្ញុំ។

ខ្ញុំអង្គុយចុះយឺតៗទាំងអារម្មណ៍ចម្លែកមួយបានកើតឡើង។ កែវនៅពីមុខខ្ញុំមានស្រាហើយជាស្រេច។

«តោះ! Cheer!!»

គេញញឹមស្របពេលដែលបេះដូងខ្ញុំរំជួលរវាងសេចក្ដីសុខ និងភាពភ្ញាក់ផ្អើលយ៉ាងមោទនៈ។ បន្ទាប់ពីនោះយើងញុំាអាហារ។

តែហេតុអ្វីពេលវេលាកន្លងទៅស្រពេចស្រពិល ហើយលឿនខ្លាំងម្ល៉េះ?

ខ្ញុំដឹងខ្លួនមកវិញ ព្រះអាទិត្យរះចិញ្ចែង ប្រជ្រៀតចូលមកតាមចន្លោះខ្ពស់ៗនៃវិមានបុរាណនេះ។ ខ្ញុំគេងពីថ្មើរណា? ក្រែងមុននេះ ខ្ញុំញុំាអាហាររាត្រីដំបូងនៅប៉ារីស?

ក្បាលខ្ញុំស្រាលដូចជាបានគេងយ៉ាងលក់ស្កប់ស្កល់ ហើយត្រូវបានដាស់ឡើងមកដោយស្នូរគោះទ្វារ។

«អូ! ហើយខ្ញុំនេះនៅស្ពឹកហ្នឹង! អត់បានត្រៀមអាហារពេលព្រឹកសម្រាប់បងរិន្ទទេ?»

ខ្ញុំក្រឡេកទៅទ្វារទាំងចិត្តអន្ទះសារ ហើយឆ្លើយតបវិញ៖

«ទៅហើយ!»

ខ្ញុំប្រញាប់ក្រោកមក ហើយសម្លឹងរកនាឡិកាប៉ោលដែលវាយម៉ោង៩ព្រឹក។

«ពុទ្ធោ! ប្ដីខ្ញុំក្រោកហួសម៉ោងធ្វើការហើយ!»

អ្នកបម្រើស្រីម្នាក់បង្ហាញខ្លួន។

នាងនេះក៏មិនខុសពីនាយម្នាក់កាលពីម្សិល សាច់ឈាមសមតែជាឥណ្ឌា ឬម៉ាឡេ ថែមទាំងធ្មឹងផ្ទាំង។

«លោកប្រុសទៅណា?»

នាងមិនឆ្លើយ។

«ចំមែន! បងរិន្ទជួលមនុស្សសុទ្ធតែអត់ចេះអង់គ្លេស! ចង់ឱ្យប្រពន្ធនេះថប់ដង្ហើមស្លាប់ហើយ!»

នាងបែរខ្លួនលើកថាសប្រាក់មួយភ្លឺរន្ទាលមកដាក់ពីមុខខ្ញុំ។

ខ្ញុំមិនខ្វល់ថាមានអ្វីនៅលើនោះខ្លះទេ តែខ្ញុំឃើញផ្កាទុយលីបពណ៌ឈូកខ្ចី ដាក់សង្កត់ពីលើលិខិតតូចមួយសរសេរជាភាសាខ្មែរ។

«បងសុំទោសដែលប្រញាប់! អាហារពេលព្រឹកនេះ បងធ្វើផ្ទាល់ដៃជូនភរិយាសំណព្វចិត្ត!»

បេះដូងខ្ញុំញញឹម ហើយដៃខ្ញុំលូកទៅទទួលទ្រថាសម្ហូប។

គេមិននៅទេ។ មិនត្រឹមតែគេមិនចេះខឹងបានប្រពន្ធខ្ជិល គេថែមទាំងជាស្វាមីល្អកម្ររក។

ខ្ញុំបិទទ្វារ ហើយស្រូតលុបមុខមាត់ផ្លាស់ខោអាវ។

មុនពេលបរិភោគ ខ្ញុំទាញទូរសព្ទមករកចុចទៅគេ តែខ្ញុំឃើញ SMS របស់គេ។

«កុំពិបាកចិត្ត! យប់បន្តិច បងនាំដើរលេងពាសពេញប៉ារីស!»

មុនម៉ោងប្រាំបីយប់ គេវិលមកវិញ....

គេប្រញាប់ប្រញាល់ហៅនាំខ្ញុំទៅកាន់ស្ថានីយ៍រថភ្លើង Gare Montparnasse ។ ប្ដីប្រពន្ធយើងអង្គុយជិតគ្នាតែពីរនាក់គយគន់ទិដ្ឋភាពខាងក្រៅយ៉ាងរ៉ូមែនទិក ឯពួកអ្នកបម្រើគេបានដកថយទៅនៅទូរថផ្សេងៗអស់ហើយ។

**ខ្ញុំចាប់ផ្ដើមសួរគេះ**

«បងរិទ្ធយកអ្នកធ្វើការក្នុងផ្ទះ សុទ្ធតែមិនចេះអង់គ្លេសមែនទេ?»

គេលូកដៃមកឱបស្មាខ្ញុំ ត្បុលខ្លួនខ្ញុំទៅក្នុងទ្រូងគេ ហើយគេដាក់មាត់ក្បែរត្រចៀកខ្ញុំទើបឆ្លើយតប ៖

«អត់ទេ! ពួកគេចេះទេតើ!»

«មិនពិតទេ! ពេលខ្ញុំសួរអ្វីមួយគ្មានអ្នកណាមករវល់ឆ្លើយសោះ!»

«ព្រោះជាបទបញ្ជា!»

«ថាម៉េច? នេះជាបទបញ្ជា? បញ្ជាមិនឱ្យឆ្លើយនឹងខ្ញុំ?»

«អត់ទេ! គឺផ្ទះនេះ! ផ្ទះពីដើមមកមានបទបញ្ជាដាច់ខាតមិនឱ្យនិយាយស្ដីទេ ពេលចូលមកធ្វើការ!»

«ថាម៉េច?» ខ្ញុំលាន់មាត់ព្រោះហួសចិត្ត។

តែគេវិញឆ្លើយតបនឹងខ្ញុំដូចជាមិនខ្វល់ថា ខ្ញុំកំពុងចម្លែកចិត្តកម្រិតណានោះទេះ

«អូនឡានីស្ដាប់ត្រូវហើយ! គឺអ្នកបម្រើមិនឱ្យនិយាយគ្នា មិនឱ្យមានសំឡេង មិនឱ្យឆ្លើយឆ្លង!»

«ស្អីអ៊ីចេះ? ហើយបងរិទ្ធគិតបែបណាដែលមានបទបញ្ជាយ៉ាប់ៗនេះ?»

«អត់មានគិតបែបណាទេ! ជាទម្លាប់តាំងពីជំនាន់ចាស់!»

«ប៉ុន្តែ!...ហ៊ឺយ! ប្រពន្ធចង់ដឹងថា ចិត្តបងរិទ្ធខ្លួនឯងវិញ ព្រមនឹងរបៀបរស់នៅចម្លែកៗស្ងាត់ជ្រងំអ៊ីចឹងៗដែរអត់?»

«បងធ្លាប់ហើយ!»

ខ្ញុំលែងនិយាយស្ដីមួយខណៈ តែចិត្តខ្ញុំចាប់ផ្ដើមរារែក។ សំណួរមួយដែលខ្ញុំភ្លេចសួរខ្លួនឯងពេលនេះបានលេចឡើងមកហើយ។ តើខ្ញុំនឹងគេអាចរស់នៅចុះសម្រុងគ្នាកម្រិតណាដែរ? អ្វីៗគ្រប់យ៉ាង

ដែលខ្ញុំបានឃើញ បានជួបក្នុងរវាងពេលជាងម្ភៃម៉ោងនៅប៉ារីសនេះ តើគ្រាន់តែប៉ុណ្ណឹងឬមានរឿងចម្លែកៗលើសហ្នឹងទៀត? ខ្ញុំទទួលយកគេបានទេ? ចំណែកគេ តើគេព្រមលះបង់ទម្លាប់ខ្លះៗសម្រាប់ប្រពន្ធក្រីក្រម្នាក់នេះបានដែរ?

ខ្ញុំនៅស្រពោន ដៃគេវាវមករកចង្កេះខ្ញុំ ហើយឱបខ្ញុំរឹតបន្តឹងជាងមុន ទំនងជាមើលដឹងពីអ្វីដែលខ្ញុំកំពុងតែតស៊ូក្នុងចិត្ត។

ខ្ញុំអៀនរឹងខ្លួន ព្រោះប្ដីប្រពន្ធតែឈ្មោះ។ ខ្ញុំមិនទាន់បានជិតដិតនឹងគេសូម្បីតែម្ដង ចំណែកគេប្រព្រឹត្តមកលើខ្ញុំដូចជាស្គាល់កាយស្គាល់ចិត្តណាស់អ៊ីចឹង។

«បងនឹងឱ្យវត្ថុល្អៗលើលោកនេះឱ្យប្រពន្ធសម្លាញ់របស់បង ហើយបងនឹងថែរក្សាអូនឱ្យសប្បាយចិត្តសោយសុខជារៀងរហូត! ឈប់ពិបាកចិត្តទៅ! ចង់បានអ្នកបម្រើចេះនិយាយកំដរ បងនឹងរកមកឱ្យជាពិសេស! ឱ្យមកចាំនិយាយជជែកជាមួយឡានី!»

ខ្ញុំនៅរក្សាភាពស្ងៀមស្ងាត់ ប៉ុន្តែចិត្តខ្ញុំអាណិតបងរិន្ទដែលខំគ្រប់បែបយ៉ាងឱ្យភរិយាសប្បាយចិត្ត។

យប់ចូលមកដល់ហើយរថភ្លើងបានឈប់។

យើងបានចូលមកដល់សណ្ឋាគារមួយ ហើយគេឱ្យខ្ញុំអង្គុយចុះក្បែរគេ ក្បែរសាឡុងរង់ចាំពួកអ្នកបែរហមទៅរកសោបន្ទប់។

អ្នកណាក៏មើលមកឃើញថា យើងជាគូស្នេហ៍ដែលជិតស្និទ្ធណាស់។ ខ្ញុំអង្គុយក្នុងរង្វង់ដៃប្ដីជានិច្ចទីណាក៏គេមិនដែលបោះបង់ចោលការឱបក្រសោបការពារខ្ញុំនោះដែរ។

«យើងគេងនៅទីនេះ ហើយពេលព្រឹកយើងទៅដើរលេង!»

គេនេះមើលទៅជាបុរសស្មោះក្លាហាន អាចធ្វើអ្វីគ្រប់សព្វបានសម្រាប់ស្ត្រីទន់ខ្សោយជាភរិយានេះ គ្រាន់តែដើម្បីឱ្យខ្ញុំសប្បាយចិត្ត? ខ្ញុំនៅស្ងៀមតែខ្ញុំញញឹម។ យើងបានឡើងទៅដល់បន្ទប់ដ៏ល្អប្រណីតមួយ។

ទីនេះមានតែខ្ញុំហើយនិងគេ ធ្វើឱ្យខ្ញុំនឹកអៀនហើយភ័យព្រួយថា ស្នេហារាត្រីដំបូងរបស់យើងនឹងប្រព្រឹត្តទៅដោយរបៀបណា? តើគេពេញចិត្តខ្ញុំដែរទេ?

ខ្ញុំឈរបែរខ្នងរៀបចំខោអាវប្ដីដាក់ក្នុងទូ តែគេដើរមកឈរពីមុខខ្ញុំ ហើយសើចយ៉ាងសង្ហា។

គេមិនមែនមកទារឱ្យខ្ញុំធ្វើភារកិច្ចជាភរិយាភ្លាមៗពេលនេះតែម្ដងទេឬយ៉ាងណា?

យើងបានដឹងយ៉ាងច្បាស់ថា ការរួមភេទសម្ព័ន្ធជារឿងធម្មជាតិ តែខ្ញុំនៅតែភ័យព្រួយ។

ខ្ញុំគេចពីគេមិនហ៊ានមើលមុខចំឡើយ។

«ចូលចិត្តបន្ទប់នេះទេ?»

គេសួរតិចៗ ខ្ញុំក៏ធ្វើជាងាកមើលជុំវិញខ្លួន ហើយសរសើរទាំងញញឹមៈ

«អស្ចារ្យណាស់!»

«នេះគ្រាន់តែជាការផ្ដើម»

«មានន័យថាម៉េច?»

«ប្ដីនឹងនាំប្រពន្ធទៅកាន់កន្លែងអស្ចារ្យទាំងឡាយលើលោកនេះ!»

«លើលោកនេះ?»

ខ្ញុំខ្សឹបសួរ ទាក់ទៅនឹងកែវភ្នែកទន់ស្លូតរបស់គេ។ គេងក់ក្បាលតបបញ្ជាក់ៈ

«បាទអូន!»

ខ្ញុំរំភើបចិត្តប្រិចភ្នែកចង់យំ។

«ហេតុអីបងរិទ្ធល្អនឹងឡានីម្ល៉េះ!»

គេស្រពោនហើយសម្លឹងមកខ្ញុំ។ ខ្ញុំពន្យល់បន្ថែមនូវទឹកចិត្តខ្លួនឯងៈ

«ឡានីឆ្ងល់ថាឡានីគ្មានអ្វីទាំងអស់! លោកនេះមានស្រីៗជាច្រើនដែល... ល្អ... ដែលស្អាត...ដែល...»

គេកាន់តែស្រពោន សម្លឹងមកខ្ញុំ ហើយខ្ញុំក៏បង្ហើយៈ

«បងរិទ្ធល្អនឹងឡានីពេកនាំតែខ្ញុំពិបាកចិត្ត ព្រោះមិនមានអ្វីសងបងរិទ្ធវិញ!»

គេដកដង្ហើមធំ ហើយនិយាយមួយៗៈ

«ឈប់គិតតែពីសតែពាសទៅ! ឡានីកើតមកជាប្រពន្ធបង បងនឹងថែរក្សាឡានីជារៀងរហូត! តោះ! រៀបចំខ្លួនទៅ យើងចុះទៅខាងក្រោម រីករាយនឹងអាហារក្រោមភ្លើងទៀន មានវិយោឡុងកំដរទៀត!» គេបង្ហាញកញ្ចប់មួយធំដល់ខ្ញុំ។

វាជារ៉ូបអីវ៉ុបវែងអន្លាយ ខ្ញុំមិនដែលប្រើទេនៅកម្ពុជា តែពេលនេះខ្ញុំចង់ពាក់ណាស់ ព្រោះវាមើលទៅស្អាតមែនទែន។

គេឱ្យខ្ញុំផ្លាស់ ហើយទាញខ្ញុំឱ្យអង្គុយមុខទូសម្អាង។

គេបើកប្រអប់យកខ្សែកពេជ្រដេញរស្មី ធ្ងន់ពេញកញ្ចឹងកមកពាក់ឱ្យខ្ញុំ។ មាត់គេនិយាយយឺតៗសុភាពរាបសាៈ

«ត្រូវជឿជាក់ថា បងនឹងចូលមកផ្លាស់ប្ដូរជីវិតឡានីឱ្យកាន់តែល្អប្រសើរជាងមុន! បងចង់ឱ្យឡានីសម្រាកក្នុងជីវិតមួយសោយសុខនិងស្មោះត្រង់នឹងប្ដីតែម្នាក់!»

គេលុតជង្គង់ចុះមក ហើយទទួលយកដៃទាំងទ្វេររបស់ខ្ញុំទៅច្របាច់តិចៗថ្នមៗ។ ខ្ញុំភ្លឹកភ្លាំងនឹងមន្តស្នេហ៍ទន់ភ្លន់របស់គេ។

គេបាននិយាយយ៉ាងច្បាស់ថា៖

«បងសុំតែចិត្តស្មោះទេ!»

«តើស្រីណាទៅមានចិត្តមិនត្រង់ ចំពោះមនុស្សជាទីស្រឡាញ់រកគ្មាននេះកើតទៅ?»

ខ្ញុំសួរវិញខ្សោយៗព្រោះចិត្តរំភើប។គេនៅញញឹមខ្ញុំក៏និយាយទៀត៖

«គឺព្រហ្មលិខិតពិតមែនទេ ដែលជាអ្នកមកកំណត់និស្ស័យរវាងពួកយើង? ឡានីសន្យានឹងបងរិទ្ធដែរថាភរិយានឹងធ្វើអ្វីទាំងអស់ដើម្បីតែប្ដីម្នាក់នេះ!»

គេឈ្ងោកមកថើបដៃរបស់ខ្ញុំខ្សឺត។

គេនេះជាបុរសខ្មែរ តែគេទន់ភ្លន់ពេកហើយ គឺមកពីអម្បូរជាអភិជនខ្ពស់កប់ពពករបស់គេទេដឹង? គេញញឹមជាមួយនឹងស្នូរដកដង្ហើមធំនៃការដែលបាននិយាយនូវអ្វីមួយស្របតាមការចង់បានរបស់គេ។

«សំណើមួយទៀត!»

គេនិយាយតិចៗទាំងជង្គង់នៅប៉ះកម្រាលព្រំនៅឡើយ។ ខ្ញុំឆ្លើយវិញដោយអន្ទះសារ៖

«អូនព្រមទាំងអស់!»

«ស្ដាប់!»

នាងនៅស្ងៀមពេលគេហើបមាត់បន្ត៖

«ប៉ុន្តែបងចង់ឱ្យឡានីសន្យាធ្វើរឿងមួយសម្រាប់ប្ដី! ពេលណាក៏ដោយ មានអ្វីកើតឡើងក៏ដោយ ត្រូវអភ័យទោស ហើយជឿថា ប្ដីនឹងថែរក្សាប្រពន្ធអស់មួយជីវិត!»

«ប៉ុណ្ណឹងគ្រប់គ្រាន់ហើយសម្រាប់ប្រពន្ធម្នាក់នេះ!»

ខ្ញុំនិយាយតបទៅគេវិញភ្លាមៗ ដោយងក់ក្បាលរលីងរលោងទឹកភ្នែក ហើយការតបនេះ ព្រោះតែមានក្ដីស្នេហាពេញក្នុងបេះដូង។

«ហេតុចម្លែក ក្ដីអផ្សុក ការរស់នៅមិនទម្លាប់ វានឹងបាត់ទៅនៅថ្ងៃណាមួយ! វាជាការសាកល្បងជីវិតប្ដីប្រពន្ធពួកយើង អូនត្រូវជម្នះវាដើម្បីបង!»

គេនិយាយបន្ថែមមកនេះ ធ្វើឱ្យខ្ញុំកាន់តែរំភើបចិត្តជាមួយគេ ហើយងក់ក្បាលទទួលព្រម សូម្បីតែចិត្តសង្ស័យមួយសរសៃក៏គ្មាន ទោះមើលទៅការនិយាយរបស់គេដូចជាប្លែកៗក្តី។

យើងចុះដល់ក្រោម ហើយចាប់ផ្តើមអាហារពេលយប់។

នេះជាភោជនីយដ្ឋានសម្រាប់តែពួកអភិជនប៉ុណ្ណោះ ព្រោះម្នាក់ៗប្រើគ្រឿងពេជ្រធំៗដូចស្រីៗក្នុងរាជវង្ស និងគ្រងអាវវែងអូសលើព្រំសមនឹងការតុបតែង សឹងតែភ្លឹកស្មារតីបាននៃបរិវេណនេះ។

«អូនស្រាប់តែងុយដល់ហើយ!»

ខ្ញុំនិយាយតិចៗ ពេលទើបតែញ៉ាំអាហារបានចប់មិនទាន់ស្រួលបួលផង។

«អូនអស់កម្លាំងពេកហ្នឹង!»

គេឆ្លើយមកវិញហាក់គ្មានខឹងសម្បារអីទាំងអស់។ ដែលគួរឱ្យខឹងនោះគឺខ្ញុំខ្លួនឯង ព្រោះថាពេលខ្ញុំបើកភ្នែកដឹងខ្លួនមកវិញ គឺព្រឹកទៀតទៅហើយ។

ឯណាទៅរាត្រីផ្សំដំណេករបស់យើង?

ស្វាមីខ្ញុំហួសចិត្តប៉ុនណាទៅដែលបានភរិយាមួយទ្រមក់កម្រិតនេះ?

ខ្ញុំក្រោកពត់ខ្លួន ហើយមានអារម្មណ៍ថានៅម្នាក់ឯង?

កុំប្រាប់ថាគេទៅធ្វើការ ទុកឱ្យខ្ញុំចាំនៅសណ្ឋាគារនេះណ៎ា?

«បងរិទ្ធ? បងរិទ្ធ? បង?»

ខ្ញុំហៅគេ។

ខ្ញុំមិនឮអ្វីទាំងអស់ ក៏ងាកយឺតៗមកពិនិត្យកម្រាលពូក និងខ្នើយមួយទៀត។ យប់មិញគេគេងជាមួយខ្ញុំដែរទេ? ហេតុអីគ្រែនេះមើលទៅដូចជា គ្មានអ្នកណាឡើងមកគេងក្រៅតែពីខ្ញុំ?

ស្នូរស្បែកជើងនៅមាត់ទ្វារ។ ខ្ញុំក្រោកទៅបើក គឺប្តីខ្ញុំ។ រូបរាងគេប្រៀបដូចជាទើបតែមកពីទីណាមួយ ដូច្នេះខ្ញុំបង្អួសភ្នែកមើលមកដៃរបស់គេ។

គេកាន់បាច់ផ្កាមួយស្រស់បំព្រង ចិត្តខ្ញុំរំភើប ហើយឱបកគេ មុនពេលគេហុចផ្កាមកទៅទៀត។

ក្លិនម្យ៉ាងជាប់នៅលើខ្លួនគេ... វាមិនមែនជាទឹកអប់ខ្ញុំប្រើ ក៏មិនមែនក្លិនមនុស្សប្រុស...!!!

បេះដូងខ្ញុំស្រាលស្បើក ហើយប្រាជ្ញាខ្ញុំលោតឡើងមក អណ្តែតចេញជាការគិតយ៉ាងច្រើន...

«យប់មិញបងរិទ្ធទៅគេងឯណា?»

ខ្ញុំសួរដោយមុខស្ងួត។